ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ១៣៨៤ ឧស.ឯ.ក

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៦

**សូមគោរពជូន**

ការប្រញាប់

- **ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាប្រធានអង្គភាពនៅថ្នាក់រដ្ឋបាលកណ្តាល**
- **ឯកឧត្តមអគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

**កម្មវត្ថុ** ៖ ស្តីពីការជំរុញធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរគំរូថ្មីជូនមន្ត្រីរាជការនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**យោង** ៖ -លិខិតលេខ១១០១ MIH/2016 ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៦ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
-សេចក្តីណែនាំលេខ០១ សណន ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៦ របស់ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោកជំទាវ លោក លោកស្រី** មេត្តាជ្រាបថា៖ នៅថ្ងៃសុក្រ ទី២២ ខែកក្កដា ឆ្នាំ២០១៦ ខាងមុខនេះ នាយកដ្ឋានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃនឹងមកធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរគំរូថ្មីជូនមន្ត្រីរាជការនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល០១ថ្ងៃ នៅសាលប្រជុំរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។

មន្ត្រីរាជការដែលត្រូវមកធ្វើអត្តសញ្ញាណប័ណ្ណ សូមភ្ជាប់មកជាមួយនូវ៖ សំបុត្រកំណើត, សៀវភៅគ្រួសារ ឬ សៀវភៅស្នាក់នៅ, អត្តសញ្ញាណប័ណ្ណចាស់ (បើមាន)។

ចំពោះមន្ត្រីរាជការ ដែលបានធ្វើអត្តសញ្ញាណប័ណ្ណគំរូថ្មីហើយ ទោះបានទទួល ឬមិនបានទទួលអត្តសញ្ញាណប័ណ្ណក្តី គឺមិនចាំបាច់មកធ្វើទៀតទេ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** មេត្តាជ្រាប និងផ្សព្វផ្សាយជូនមន្ត្រីរាជការក្រោមឱវាទ ដើម្បីមកធ្វើអត្តសញ្ញាណប័ណ្ណឲ្យបានគ្រប់ៗគ្នាតាមកាលបរិច្ឆេទខាងលើ តាមការគួរ។

**ត.ប រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**អគ្គនាយករងកិច្ចការទូទៅ**

**ជួរ ជេតទីវត្ត**

ចម្លងជូន៖
-ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
-ឯកសារ-កាលប្បវត្តិ